ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងខែកុម្ភៈ ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុនៅតែទទួលរងឥទ្ធិពលពីជ្រលងសម្ពាធខ្ពស់ ផ្ទៃមេឃមានពពកតិចនិងខ្យល់បក់មកពីទិសបូព៌ានិងអគ្នេយ៍។ ប្រជាកសិករបាននិងកំពុងជំរុញដំណើរការការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៣-២០១៤ ក្នុងនោះដំណាំស្រូវសម្រេចបាន១២៧,១១% នៃផែនការដាំដុះ។ ទន្ទឹមនឹងនេះ ការងារប្រមូលផលដំណាំស្រូវរដូវប្រាំងបាននិងកំពុងដំណើរការជាបណ្តើរៗហើយ ដោយសម្រេចបាន២៦,៥៤% នៃផ្ទៃដីអនុវត្តបាន។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៤៣.៩៨៦ហិកតា តិចជាងឆ្នាំមុនចំនួន១.៩១៣ហិកតា

-ផ្ទៃដីសាបសរុបចំនួន៤.៨៥៤ហិកតា តិចជាងឆ្នាំមុនចំនួន៥៥៩ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៨៧.៥០៦ហិកតា ស្មើនឹង១២៧,១១ភាគរយ នៃផែនការ៣៨៣.៥៣០ហិកតា តិចជាងឆ្នាំមុនចំនួន៦.៣៦៧ហិកតា

-ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដីចំនួន១២៩.៣៧៩ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៥៦៩.៩៨៩តោន និងទិន្នផលជាមធ្យមចំនួន៤,៤០៦តោនក្នុងមួយហិកតា។

#### ១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៨២.១៤០ហិកតា ស្មើនឹង១៨៨,៦៤ភាគរយ នៃផែនការសរុប៤៣.៥៤៤ហិកតា តិចជាងឆ្នាំមុន៣១.៧៣៥ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន២១.១១៣ហិកតា (ក្នុងនោះពោតក្រហមចំនួន១៥.៦៦២ហិកតា) តិចជាងឆ្នាំមុន១៩.២៣១ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន២៥.២៦៩ហិកតា តិចជាងឆ្នាំមុន៥.២៨៦ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន២.៦១៧ហិកតា តិចជាងឆ្នាំមុន៦៧៩ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២១.១៥៣ហិកតា តិចជាងឆ្នាំមុន២.៦៣៣ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន១១.៩៨៨ហិកតា តិចជាងឆ្នាំមុន៣.៩០៦ហិកតា ។

#### ១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១២.២៩១ហិកតា ស្មើនឹង៦១,៣២ភាគរយ នៃផែនការសរុប ២០.០៤៤ហិកតា តិចជាងឆ្នាំមុន៥.២៣៦ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន២.៥១៧ហិកតា តិចជាងឆ្នាំមុន៤៧ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

-ផ្ទៃដីសណ្ដែកសៀងចំនួន២៦ហិកតា តិចជាងឆ្នាំមុន២.៥៦៩ហិកតា

-ផ្ទៃដីល្ងចំនួន១.៦៨៦ហិកតា តិចជាងឆ្នាំមុន៥៧៥ហិកតា

-ផ្ទៃដីអំពៅចំនួន២.១៦៧ហិកតា តិចជាងឆ្នាំមុន១.១៤២ហិកតា

-ផ្ទៃដីក្រចៅចំនួន៤១ហិកតា លើសឆ្នាំមុនចំនួន១ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន៥.៨៥៤ហិកតា តិចជាងឆ្នាំមុន៩០៥ហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ការបរិយាយ | ឯកត្តា | ក្រុមហ៊ុនចម្ការកៅស៊ូ កសិ-ឧស្សាហកម្ម | ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ចម្ការកៅស៊ូ គ្រួសារ-ឯកជន | សរុប |
|---|---|---|---|---|---|
| ផ្ទៃដីសម្បទាន | ហិកតា | ៧៣,៩០៦ | ៥៣៩,៥៧៤ | - | ៦១៣,៤៨០ |
| ផ្ទៃដីចៀរ | ហិកតា | ២៦,០៣៨ | - | ៥២,៥១៦ | ៧៨,៥៥៤ |
| ផ្ទៃដីថែទាំ | ហិកតា | ២៩,៨៧០ | ១៣៥,៤៤៦ | ៨៤,៩០១ | ២៥០,២១៧ |
| **សរុប** | **ហិកតា** | **១២៩,៨១៤** | **៦៧៥,០២០** | **១៣៧,៤១៧** | **៩៤២,២៥១** |
| ការប្រមូលផល | តោន | ១,០៩០ | - | ២,១៩៩ | ៣,២៩០ |
| ការបញ្ចេញលក់ | តោន | ១,០៩០ | - | ២,១៩៩ | ៣,២៩០ |

### ២.២ ការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

-ជួបពិភាក្សាជាមួយក្រុមការងារអង្គការ UNIDO ដើម្បីកំណត់ការពង្រីកវិសាលភាពតេស្តដល់ផលិតផលសម្រេចពីកៅស៊ូដែលជាជំនួយរបស់អង្គការ UNIDO

-ធ្វើទស្សនកិច្ចស្វែងយល់ពីសកម្មភាពការងាររបស់ក្រុមប្រឹក្សា IRRDB និង MRB នៅប្រទេសម៉ាឡេស៊ី ជាពិសេសពាក់ព័ន្ធនឹងកម្មវិធីដែលជាប្រយោជន៍រួម និងពង្រីកកិច្ចសហប្រតិបត្តិការដែលមានស្រាប់។

### ២.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ត្រួតពិនិត្យការបំប៉ៅកូនកៅស៊ូសម្រាប់ឡូត៍ពិសោធន៍នៅខេត្តសៀមរាប

-វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍កូននៅវិទ្យាស្ថានចម្ការកៅស៊ូជុប និងចម្ការកៅស៊ូក្រែក។

### ២.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-តាមដានស្រង់ទិន្នន័យចម្ការកៅស៊ូពិសោធន៍ ត្រួតពិនិត្យការចៀរជ័រ និងជំងឺស្ងួតមុខចៀរនៅចម្ការពិសោធន៍កៅស៊ូក្រែក។

### ២.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-តាមដាននិងស្រង់ទិន្នន័យទិន្នផលចម្ការពិសោធន៍ និងថែទាំសមូហកម្មពូជដំណាំគម្របដី។

### ២.៦ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តភាគសំណាកយថាប្រភេទបានចំនួន១៥ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកៅស៊ូជ័ររបស់រោងចក្រក្រុមហ៊ុនឡុងស្រេង គ្រុប ខូអិលធីឌី។

### ២.៧ ការងារនៅស្ថានីយអនុវត្ត

-បំប៉ៅកូនកៅស៊ូបានចំនួន១៣.០៧៧កូន ស្មើ៤៤ពូជ និងកាត់ខ្នែងនៅឡូត៍ដាំឆ្នាំ២០១១ដល់ឆ្នាំ២០១៣ បានចំនួន៤៣,៧៥ហិកតា និងភ្ជួរដីតាមចន្លោះរងកៅស៊ូបានចំនួន១៨,៧៥ហិកតា។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣៤៩ក្បាល ក្នុងនោះជ្រូកបាចំនួន១២ក្បាល ជ្រូកមេទំនេរចំនួន១៣៣ក្បាល និងកូនជ្រូកចំនួន២០៤ក្បាល។

-គោសរុបចំនួន២០៣ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦៤ក្បាល គោជំទង់ចំនួន ៥៣ក្បាល គោបៅដោះចំនួន៤៤ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

## ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន២៤.០០៨ក្បាល និងជំងឺអុតក្ដាមចំនួន១.៩២៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន២.៥៦១ក្បាល ជំងឺប៉េស្តចំនួន៤.៨៦៦ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៣.៦០៦ក្បាល ជំងឺអុតក្ដាមចំនួន៨០ក្បាល ជំងឺអូហ្យេស្គីចំនួន៥៧៩ក្បាល ជំងឺកញ្ជ្រឹលចំនួន១០ក្បាល និងជំងឺជាតិដែកចំនួន៧២ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៥.៨៥០ក្បាល ជំងឺញ៉ូកាសចំនួន៨.៨០៦ក្បាល ជំងឺប៉េស្តទាចំនួន ១.៨០០ក្បាល ជំងឺរាសន្ទរោគចំនួន៦.៦៧៧ក្បាល និងជំងឺហ្គមបូរូចំនួន២១២ក្បាល។

## ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្ដាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន៥០៦សំណាក

-ផ្នែកសរីរោគសាស្ត្រសរុបចំនួន០៧ក្បាល ។

## ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានប្រជុំពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីកម្រិតអន្តរក្រសួងចំនួន២លើក

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន១៦ករណី មកពីតាមបណ្តារាជធានី ខេត្ត វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងក្រសួងសុខាភិបាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-ក្នុងខែកុម្ភៈនេះ មានករណីផ្ទុះជំងឺផ្តាសាយបក្សីដែលបង្កដោយវីរុសH5N1 លើបក្សីនៅភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល និងនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ

-តាមដាន ឃ្លាំមើលជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្ត

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន៨លើក កន្លែងចិញ្ចឹមមាន់ចំនួន២៣លើក កន្លែងចិញ្ចឹមទាចំនួន១លើក ទ្រុងចិញ្ចឹមចំនួន៧លើក បរិវេណភូមិចំនួន៤លើក សត្តឃាតដ្ឋានចំនួន២២លើក និងផ្លូវជាតិចំនួន១លើក

-ត្រួតពិនិត្យការដឹកជញ្ជូនក្របីចំនួន១១ករណី ជ្រូកចំនួន២៩ក្បាល មាន់ចំនួន៤.៨៧៨ក្បាល ស៊ុតចំនួន ៥០.០០០ក្បាល ស្បែកគោ-ក្របីចំនួន១៤.៨៣០ក្បាល ផលិតផលខូចគុណភាពចំនួន១.៨០៤គ.ក្រ និងពិន័យជាប្រាក់ចំនួន៣០.៥០០.០០០រៀល

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

## ៣.៥ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន១៧០ឡ។

# ៤ ផ្នែកព្រៃឈើ

## ៤.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៧.១៥៨.០៥២.១៤១រៀល និងផ្តល់សេវាសាធារណៈចំនួន ១.០៨៨.៣៥៣.២៦២រៀល។

## ៤.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០៥ ។

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ២៥.១៦៤ម៣ ឈើអារចំនួន៣៥ម៣ ឈើជ្រុងចំនួន៣.៨៥២ម៣ កូនឈើចំនួន១០.០៤២ដើម និងអុសចម្រុះចំនួន៣.០៧១ស្ទែរ។

## ៤.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអន្លង់ព្រីង តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួនប្រមាណ១៨០ប្រភេទ ស្មើនឹងជាង២៨៣៣ក្បាល

-រៀបចំអាហារដ្ឋានត្មាតចំនួន០២លើក នៅតំបន់ព្រៃការពារមណ្ឌលគិរី និងតំបន់អភិរក្សជីវចម្រុះសៀមប៉ាង ដោយរាប់ឃើញត្មាតសរុបចំនួនប្រមាណជាង៨០ក្បាល

-ការពារសម្បុកត្រយ៉ងចង្កំកសចំនួន១៥និងត្មាតចំនួន៧ នៅតំបន់សៀមប៉ាងភាគខាងលិចនិងតំបន់ទន្លេមេគង្គលើ។

## ៤.៤ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន១២លើក ស្តីពីច្បាប់ស្តីពីព្រៃឈើនិងលិខិតបទដ្ឋាននានាពីសារៈសំខាន់សត្វព្រៃ និងជីវចម្រុះ ការកាប់រានដីព្រៃ ការប្រើឧបករណ៍នេសាទខុសច្បាប់ ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៩២៤នាក់ ស្រ្តីចំនួន៣៣១នាក់។

## ៤.៥ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជសត្វក្តាម និងការសង្គ្រោះសត្វព្រៃ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន១៥៣ក្បាល សត្វកើតថ្មីចំនួន១០ក្បាល សត្វដោះលែងចំនួន១៤៧ក្បាល សត្វស្លាប់ចំនួន១៧ក្បាល ព្យាបាលសត្វចំនួន៣៨ក្បាល យកសំណាកទៅពិសោធន៍ចំនួន១៦ក្បាល ធ្វើឲ្យសន្លប់ចំនួន៣៥ក្បាល ទម្លាក់សត្វល្អិតចំនួន២ក្បាល វះកាត់សាកសពសត្វចំនួន៧ក្បាល ដាក់លេខកូដចំនួន២១ក្បាល ចាក់វ៉ាក់សាំងចំនួន២៧៤ក្បាល ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៤ម២ ជួសជុលផ្លូវចំនួន២៤.៤២០ម២ ឆ្ការអនាម័យព្រៃចំនួន១៣៥.៩៤៦ម២ ដាំកូនឈើចំនួន៣ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៤.៣០៥ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន ១.២៨៨នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមសត្វក្តាមមេ-បាពូជ និងកូនសត្វក្តាមចំនួន៥៧.៥១១ក្បាល។

## ៤.៦ គម្រោងអភិរក្សសត្វក្រពើកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-បន្តថែរក្សាកូនក្រពើចំនួន២៧ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្ពារក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-ក្រពើភ្នំពូជសុទ្ធចំនួន០៨ក្បាល ត្រូវបាននាំយកពីឧទ្យានសួនសត្វភ្នំតាម៉ៅ ទៅដោះលែងសាកល្បងនៅស្ទឹងកំពុងតាជៃ ភូមិពោធិ៍បឹង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ដោយមានបំពាក់ឧបករណ៍វិទ្យុសម្លេង (Radio transmitter) លើក្រពើចំនួន០៥ក្បាល

-បន្តការចុះស្រាវជ្រាវពូជឈើនៅខេត្តសៀមរាបនិងខេត្តកំពង់ធំ និងថែទាំចម្ការពូជឈើនៅខេត្តព្រះសីហនុនិងស្វាយរៀង។

## ៤.៧ ការងារដាំដើមឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៤របស់រដ្ឋបាលព្រៃឈើ បណ្តុះកូនឈើសម្រាប់ដាំជាចម្ការបានចំនួន

២៣០.០០០ដើម ឈូសឆាយដីព្រៃបានចំនួន៦៥ហិកតា និងស្ថានីយដាំឈើចំនួន១០ មានចម្ការឈើចាស់ចំនួន៣.៣១៨ហិកតា

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានកាប់ឆ្ការនិងឈូសឆាយសម្អាតដីចំនួន១៣៥ហិកតា

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Oji (Cambodia) Plantation បានឈូសឆាយសម្អាតដីចំនួន៨០ហិកតា

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីចំនួន២៥០ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត៖ បណ្តុះកូនឈើគ្រប់ប្រភេទចំនួន៦០.០២០ដើម និងចែកចាយកូនឈើបានចំនួន៥.០៧៥ដើម

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ។

## ៤.៨ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

### ៤.៨.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញចំនួន០១ក្រុមហ៊ុន សរុបចំនួន៩.៩២០,៥៨៨ម៣ ។

### ៤.៨.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០២ ស្មើនឹង៥៣សន្លឹក ដែលមានបរិមាណឈើចំនួន៧.៧៨៨,៧០២ម៣

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង០៣សន្លឹក ដែលមានបរិមាណឈើចំនួន១៥៤ម៣។

## ៤.៩ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃដោយបញ្ជូនទៅតុលាការសរុបចំនួន១៣៦ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣០,៧៧៣ម៣ ឈើអារចំនួន២០៣,៣៩៧ម៣ ឈើក្រាក់គ្រញូងចំនួន២,២១៥ម៣ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន៣២,៥៩០ហិកតា។

# ៥ ផ្នែកជលផល

## ៥.១ អាជីវកម្មនេសាទ

### ៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ ក្នុងខែចំនួន៣.០០០តោន សរុបបានចំនួន១៩.០០០តោន ស្មើ១២៦,៦៧% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន៤០.០០០តោន សរុបបានចំនួន៩០.០០០តោន ស្មើ២៣,០៨% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១០.០០០តោន សរុបបានចំនួន៣០.០០០តោន ស្មើ១៦,៦៧% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០តោន ។

### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

-អនុវត្តក្នុងខែចំនួន៩.០០០តោន បានសរុបចំនួន១៨.០០០តោន ស្មើ១៦,៣៦% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.៥០០តោន។

### ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៧.៥០០តោន សរុបបានចំនួន១៤.៥០០តោន ស្មើ១៤,៥០% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.៥០០តោន

-ការចិញ្ចឹមក្រពើ ក្នុងខែចំនួន១៥.០០០ក្បាល សរុបបានចំនួន២៥.០០០ក្បាល ស្មើ៨,៣៣% នៃផែនការ ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១២.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួន១០.០០០.០០០កូន សរុបបានចំនួន១៨.០០០.០០០កូន ស្មើ១១២,៥០% នៃផែនការ១៦.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០.០០០កូន ។

### ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៧.០០០តោន សរុបបានចំនួន១៥.០០០តោន ស្មើ១០% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ ក្នុងខែចំនួន៨០០តោន សរុបបានចំនួន១.៧០០តោន ស្មើ២១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០០តោន

-ការផលិតទឹកត្រី ក្នុងខែចំនួន៦.០០០.០០០លីត្រ សរុបបានចំនួន១០.០០០.០០០លីត្រ ស្មើ១៦,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន២.២០០តោន ស្មើ១១% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០០តោន

-ផលនេសាទកែច្នៃ ក្នុងខែចំនួន៧០០តោន សរុបបានចំនួន១.៥០០តោន ស្មើ១៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន២២៣ករណី ដែលកើតមាននៅតំបន់ទឹកសាប២១៤ករណី និងតំបន់សមុទ្រ ៩ករណី ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៥៦ករណី គឺតំបន់ទឹកសាប១៥៤ករណីនិងតំបន់សមុទ្រ២ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល ក្នុងខែចំនួន៤៣.០០២.២៥០រៀល សរុបបានចំនួន៥៦៤.២៧២.២៥០រៀល ស្មើ ១៨,៥៥% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២៤៥.៤០៣.២៥០រៀល។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤៣៨ច្បាប់ សរុបចំនួន៩៧៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៤៨ច្បាប់ សរុបចំនួន៧៤៧ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១០២ច្បាប់ សរុបចំនួន២១៣ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៧០១ច្បាប់ សរុបចំនួន១.៣៣០ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៤៩ច្បាប់ សរុបចំនួន១០៥ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៩៨ច្បាប់ សរុបចំនួន១៣៧ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកកសិឧស្សាហកម្ម

-ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិ និងពង្រឹងការកសាងស្តង់ដារម្ហូបអាហារ និងការចូលរួមសកម្មភាពកូដិចនៅកម្ពុជា នៅសណ្ឋាគារ International Phnom Penh រយៈពេល ០៣ថ្ងៃ

-ពិនិត្យនិងផ្តល់មតិលើសំណើសុំចូលរួមជួបជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ របស់សហគមន៍ប្រជាពលរដ្ឋខ្មែរអង្គរអភិវឌ្ឍន៍ ក្រុមហ៊ុនសំណង់ ឆាងឈីមស៊ិនចូវ និងក្រុមហ៊ុនដេគ័រ ឆាងឈីមស៊ិនចូវ ឬហៅម្យ៉ាងទៀតថាក្រុមហ៊ុន មហាកំផែងវិស្វកម្មសំណង់ស៊ីណូ នៃសាធារណៈរដ្ឋប្រជាមានិតចិន សហការគ្នាក្នុងគោលបំណងស្វែងរកប្រាក់កម្ចីសម្បទានពីធនាគារមកធ្វើការវិនិយោគដាំដុះដំណាំស្រូវ និងកែច្នៃជាអង្ករលើផ្ទៃដី៧២០.៥២០ហិកតាជាមួយកសិករប្រមាណ៤៨២.៣៨០គ្រួសារ ស្ថិតក្នុងខេត្តបន្ទាយមានជ័យ

-រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០១៥-២០១៧

-កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម

-ទទួលរបាយការណ៍ពីមន្ទីរកសិកម្មស្តីពីសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។

## ៨ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចូលរួមក្នុងពិធីបុណ្យដារលាន នៅភូមិព្រៃទទឹង ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល

-រៀបចំបើកវគ្គបណ្តុះបណ្តាលគ្រូជំនាញបង្គោលស្តីពីបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ និងធ្វើជាគ្រូឧទ្ទេសនាមទៅលើប្រធានបទបសិដ្ឋកម្មពូជស្រូវនៅកម្ពុជា និងគោលការណ៍ផលិតកម្មគ្រាប់ពូជស្រូវ ដែលមានអ្នកចូលរួមចំនួន៣០នាក់

-ទទួលជួបសម្ភាសន៍ និងថតជាខ្សែវីដេអូខ្លីជាមួយស្ថានីយ៍ទូរទស្សន៍ NHK របស់ប្រទេសជប៉ុន ដែលទាក់ទងនឹងស្ថានភាពទូទៅនៃផលិតកម្មដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា និងកិច្ចអន្តរាគមន៍មួយចំនួនដើម្បីចូលរួមក្នុងការជំរុញឲ្យសម្រេចបាននូវផែនការនាំចេញអង្ករឲ្យបានយ៉ាងតិច១លានតោននៅក្នុងឆ្នាំ២០១៥ ដោយផ្តោតជាពិសេសលើការអភិវឌ្ឍន៍វិស័យផលិតកម្មគ្រាប់ពូជសុទ្ធ

-បន្តការងារពិសោធន៍ស្រាវជ្រាវប្រមូលទិន្នន័យ

-ចុះប្រមូលព័ត៌មាននិងប្រជុំពិភាក្សាជាមួយកសិករ នៅខេត្តកំពង់ចាម

-ចុះប្រជុំនិងត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះសីហនុនិងផ្តល់សម្ភារៈរៀបចំដីពិសោធន៍ នៅខេត្តកំពង់ស្ពឺ

-ចុះជ្រើសរើសទីកន្លែងនិងប្រគល់សម្ភារៈពិសោធន៍នៅខេត្តកំពតនិងខេត្តព្រៃវែង

-ចុះពិនិត្យការងារពិសោធន៍របស់គម្រោង ACIAR CSE2009/037 នៅខេត្តតាកែវ

-បន្តបញ្ចូលទិន្នន័យនិងសរសេររបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០១៤។

## ៩ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥១២នាក់(ស្រី៤៤៧នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍(ទូទៅ)ចំនួន១.១០៤នាក់ ក្នុងនោះស្រី៤០៨នាក់

-និស្សិតបង់ថ្លៃចំនួន១៨៤នាក់ ក្នុងនោះស្រី៣១នាក់

-និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន២២៤នាក់ ក្នុងនោះ ស្រី៣៨នាក់។

### ៩.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។៚

### ៩.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៣នាក់ (ស្រី១.៣៩៦នាក់)។ ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-ចុះអនុស្សរណៈយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានរបស់ប្រទេសម៉ាឡេស៊ីចំនួន៣គឺ University of Malaya, BENA និង International University of Malaya-Wales និងជាមួយ Swansea University ប្រទេសអង់គ្លេស។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៣នេះបានបញ្ចប់ជាស្ថាពរហើយ ទន្ទឹមនឹងនោះ ការងារបង្កបង្កើនផលដំណាំនារដូវប្រាំង ជាពិសេសដំណាំស្រូវសម្រេចបានលើសផែនការ ហើយនឹងឈានជិតបញ្ចប់ការដាំដុះដែរ។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវក៏ដូចជាការថែទាំដំណាំផ្សេងៗនិងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ព្រមទាំងរក្សាទឹកទុកឲ្យបានគត់មត់នៅចុងរដូវ ហើយនិងទុកដាក់រក្សាផលស្រូវឲ្យបានត្រឹមត្រូវ។ ដោយឡែក គ្រប់មុខព្រួញទាំងអស់តាមវិស័យនីមួយៗបានធ្វើការប្រជុំបូកសរុបវាយតម្លៃអំពីសមិទ្ធផលរបស់ខ្លួនក្នុងឆ្នាំ២០១៣ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៤ ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលដើម្បីជាត្រីវិស័យអនុវត្តបន្តក្នុងស្មារតីទទួលខុសត្រូវ។

## V- ទិសដៅ

-បន្តតាមដានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ និងវាយតម្លៃទិន្នផល និងបរិមាណផលទទួលបានឲ្យបានច្បាស់លាស់

-សហការជាមួយអាជ្ញាធរដែនដីធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាកសិករឲ្យយកចិត្តទុកដាក់ជំរុញការងារមុនប្រមូលផល និងក្រោយពេលប្រមូលផលស្រូវ ដោយត្រូវប្រមូលផ្តុំរក្សាទុកដាក់ក្នុងជម្រុកឱ្យបានល្អតាមបច្ចេកទេសដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារផង និងការលៃទុកពូជផង

-តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវប្រាំង ដើម្បីណែនាំជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរមូលដ្ឋាន សម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង និងចាំបាច់។ សម្រាប់ស្រូវរដូវប្រាំងត្រូវបន្តផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ ជាពិសេសពូជ IR 66 ពូជផលសារ។ល។

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយ ជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវវស្សា ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-បន្តអប់រំផ្សព្វផ្សាយដល់ប្រជាកសិករដែលធ្វើស្រូវចម្ការឱ្យប្តូរពូជស្រូវដើម្បីបង្កើនទិន្នផលនិងយកចិត្តទុកដាក់ជំរុញការប្រុងប្រយ័ត្នបង្ការភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ

-ពិនិត្យ និងពង្រឹងឡើងវិញនូវមធ្យោបាយនិងសម្ភារៈផ្សេងៗដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍មានដូចជាៈ ស្រូវ ពូជនិងពូជបន្លែ មធ្យោបាយនានាសម្រាប់អន្តរាគមន៍ដល់គ្រោះរាំងស្ងួត (អន្តរាគមន៍បូមបាច) និងមធ្យោបាយ សម្ភារៈនានាដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្នាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ការកែច្នៃផលនេសាទទឹកសាប ការកែច្នៃផលនេសាទសមុទ្រ ការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដានិងរុក្ខទិវា៩កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផលនិងព្រៃឈើ

-ត្រៀមរៀបចំសន្និបាតកសិករដើម្បីជ្រើសរើសកសិករឆ្នើមទូទាំងប្រទេសនិងសន្និបាតកសិកម្មដើម្បីវាយតម្លៃពីសមិទ្ធផលដែលសម្រេចបាននៅឆ្នាំ២០១៣និងលើកទិសដៅអនុវត្តបន្តនៅឆ្នាំ២០១៤-២០១៥

-ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការអនុវត្តអនុសាសន៍ប្រកបដោយគតិបណ្ឌិតរបស់ តេជោសែន អំពីការដំឡើងកាំប្រាក់មន្ត្រីរាជការឲ្យបានលឿនដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការឲ្យខិតខំប្រឹងប្រែងធ្វើការប្រកបដោយប្រសិទ្ធភាព

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន